<u>**មេរៀនសង្ខេប**</u>

- គ្រប់សកម្មភាពទាំងអស់របស់សារពាង្គកាយរស់ ត្រូវការប្រូតេអ៊ីនជាចាំបាច់ ។ វាជាសមាសធាតុគ្រឹះនៃជីវិត។ប្រូតេអ៊ីនជាសារធាតុសាំញ៉ាំដែលផ្ទុកកាបូន អ៊ីដ្រូសែន អុកស៊ីសែន និង អាសូត ជួនកាលមានផូស្វាតនិងស្ពាន់ធ័រផងដែរ ។ សមាសធាតុគ្រឹះរបស់ប្រូតេអ៊ីនជាសារធាតុងាយគឺ អាស៊ីតអាមីណេ ។ អាស៊ីតអាមីណេនីមួយៗ ផ្សំឡើងដោយបណ្តុំអាមីន បណ្តុំកាបុកស៊ីល និងរ៉ាឌីកាល់ R ។ ក្នុងសារពាង្គកាយមនុស្ស មានអាស៊ីតអាមីណេប្រហែល20ប្រភេទខុសៗគ្នា។ អាស៊ីតអាមីណេទាំង 20 ប្រភេទនេះខុសគ្នាដោយសាររ៉ាឌីកាល់ (R) ។
- ចំណងដែលចងភ្ជាប់អាស៊ីតអាមីណេពីមួយទៅមួយ ហៅថាចំណងប៉ិបទីត ។ នៅពេលអាស៊ីត អាមីណេពីរភ្ជាប់គ្នា វាត្រូវបាត់បង់ទឹកមួយម៉ូលេគុល ។ នៅពេលអាស៊ីតអាមីណេច្រើនភ្ជាប់គ្នា បង្កើតបានជាច្រវាក់ប៉ូលីប៉ិបទីត ។ ច្រវាក់ប៉ូលីប៉ិបទីតច្រើនបង្កើតជាទម្រង់ផ្សេងៗនៃប្រូតេអ៊ីន ។ តំណលំដាប់អាស៊ីតអាមីណេ ជាអ្នកកំណត់ទម្រង់ និងនាទីរបស់ប្រូតេអ៊ីន ។